**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ៤៤៣៧ ព.ណ...កសប

ថ្ងៃអង្គារ ៧រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ ២០១៩

**ជម្រាបមក**

**លោក/លោកស្រីប្រធាន ក្រុមហ៊ុន គង់ ឡូន គ្រុប**

**កម្មវត្ថុ:** ការបន្តសុពលភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលសំបកកង់ និងពោះវៀនកង់យានយន្ត (ដោយមិនរាប់បញ្ចូលសំបកកង់ និងពោះវៀនកង់ដែលប្រើប្រាស់សម្រាប់ ផ្លូវរលាក់ យន្តហោះ ម៉ូតូប្រណាំង និងរថយន្តប្រណាំង) ម៉ាក **BRIDGESTONE** ក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **គង់ ឡូន គ្រុប**។

**យោង:** - មាត្រា ៣ និងមាត្រា ១១ នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតរបស់ក្រុមហ៊ុន **គង់ ឡូន គ្រុប** ចុះថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១៩
- លិខិតកត់ត្រាទទួលស្គាល់សិទ្ធិផ្តាច់មុខលេខ ០៦៣៨ ព.ណ កសប ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៨
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន BRIDGESTONE CORPORATION ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៩
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន Bridgestone Asia Pacific Pte. Ltd. ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៩
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/៥៥១៥/៩៥ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក/លោកស្រីប្រធានថា ក្រសួងពាណិជ្ជកម្មឯកភាពបន្តសុពលភាព កត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលសំបកកង់ និងពោះវៀនកង់យានយន្ត (ដោយមិនរាប់បញ្ចូលសំបកកង់ និងពោះវៀនកង់ដែលប្រើប្រាស់សម្រាប់ ផ្លូវរលាក់ យន្តហោះ ម៉ូតូប្រណាំង និងរថយន្តប្រណាំង) ពាក់ម៉ាកខាងលើក្នុងព្រះរាជាណាចក្រកម្ពុជា របស់ក្រុមហ៊ុន **គង់ ឡូន គ្រុប** ដែលទទួលបានពីក្រុមហ៊ុន BRIDGESTONE CORPORATION ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិនាំចូលផ្តាច់មុខរបស់ម្ចាស់ម៉ាកដែលក្រសួងបានតម្កល់ទុករួចហើយ ។

លិខិតបន្តសុពលភាពកត់ត្រានេះ មានសុពលភាពរយៈពេល ០២(ពីរ) ឆ្នាំ ដោយគិតចាប់ពីថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០២០ ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិវិញ មុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន BRIDGESTONE CORPORATION ដែលជាម្ចាស់ម៉ាក ។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ត្រូវបោះពុម្ពផ្សាយលិខិតកត់ត្រានេះក្នុងទំព័រខាងមុខសារព័ត៌មានល្បីៗភ្លាមយ៉ាងតិចចំនួន ៣(បី) លេខជាប់ៗគ្នា និងត្រូវអនុវត្តឲ្យបានត្រឹមត្រូវនូវលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**អ៊ុក ប្រាជ្ញ**

<u>ចម្លងជូន:</u>
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី ស ខេង*
- *ខុទ្ទកាល័យ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ*
- *ខុទ្ទកាល័យ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *អគ្គនាយកដ្ឋានកាំកុងត្រូល*
- *អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*
- *អគ្គនាយកដ្ឋានពន្ធដារ*
- *ឯកសារ - កាលប្បវត្តិ*

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469